VT5

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១១៦...សសរ

## សេចក្តីសម្រេច

### ស្តីពី

### ការបង្កើតលេខាធិការដ្ឋានអន្តរក្រសួងសម្រាប់ដឹកនាំការអនុវត្តកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ( Agriculture Sector Development Program ) ក្រោមឥណទានកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ( ADB )

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញឯកសារជំនួយស្មារតី ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០២ របស់ធនាគារអភិវឌ្ឍន៍អាស៊ី

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### ស ម្រេ ច

**ប្រការ១** : បង្កើតលេខាធិការដ្ឋានអន្តរក្រសួងសម្រាប់ដឹកនាំការអនុវត្តកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ក្រោមឥណទានកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ប្រធាន |
| ២- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- តំណាងក្រុមប្រឹក្សាស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ | សមាជិក |
| ៤- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៥- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៦- តំណាងក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| ៧- តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៨- តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៩- តំណាងក្រសួងកិច្ចការនារី និង អតីតយុទ្ធជន | សមាជិក |
| ១០-តំណាងក្រុមប្រឹក្សាគោលនយោបាយដីធ្លី | សមាជិក |
| ១១-អគ្គនាយករង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | លេខាធិការ |

VT5



ប្រការ២ : លេខាធិការដ្ឋាននេះ មានភារកិច្ច ទទួលខុសត្រូវរួម លើការអនុវត្តកម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ( ASDP ) ។

ប្រការ៣ : សមាជិកនៃលេខាធិការដ្ឋាននេះ ត្រូវជួបប្រជុំតាមការអញ្ជើញរបស់ប្រធានយ៉ាងតិចបំផុត១ត្រីមាសម្តង ដើម្បីពិនិត្យលើការវិវត្តន៍នៃការអនុវត្ត និង ដោះស្រាយលើរាល់បញ្ហាដែលទាក់ទងដល់ការអនុវត្តជាក់ស្តែងរបស់កម្មវិធី ដោយត្រូវរាយការណ៍ពីលទ្ធផលជូនទៅក្រុមប្រឹក្សាស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ និង ធនាគារអភិវឌ្ឍន៍អាស៊ី ។

ប្រការ៤ : លេខាធិការដ្ឋាននេះ មានទីស្នាក់ការនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងប្រើត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ប្រការ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន អនុប្រធានក្រុមប្រឹក្សាស្តារ និង អភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ . ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៣

សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ-កាលប្បវត្តិ